# នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

| | |
|---|---|
| សំណុំរឿងលេខ: | ០០៣/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស |
| ភាគីដាក់ឯកសារ: | *មិនមែនជាភាគី*-សាស្ត្រាចារ្យ Ben SAUL |
| ដាក់ជូន: | ក្រឡាបញ្ជីការិយាល័យសហចៅក្រមស៊ើបអង្កេត<br>Chhay.chanlyda@eccc.gov.kh |
| ភាសាដើម: | អង់គ្លេស |
| កាលបរិច្ឆេទឯកសារ: | ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៦ |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 24-Jun-2016, 13:20
CMS/CFO: Sann Rada

ចំនួនទំព័រសរុប: ១០ទំព័រ(បូកបន្ថែមជាមួយតារាងសិទ្ធិអំណាច(២ទំព័រ) និងឧបសម្ព័ន្ធ១-៣(២១ទំព័រ)

---

**សារណាមិនមែនជាភាគីនៅក្នុងសំណុំរឿង ០០៣ និង ០០៤-សាស្ត្រាចារ្យ BEN SAUL**

---

**<u>ដាក់ដោយ÷</u>**

សាស្ត្រាចារ្យ Ben SAUL
ben.saul@sydney.edu.au

01298866



## សេចក្តីផ្តើម

១. សារណាមិនមែនជាភាគីនេះ(“សារណា”) ឆ្លើយតបទៅនឹងសេចក្តីអំពាវនាវឲ្យដាក់សារណាពីអ្នកដែលមិនមែនជាភាគីនៅក្នុងសំណុំរឿង ០០៣ និង ០០៤ ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១៦ (“សេចក្តីអំពាវនាវ”) ចំពោះបញ្ហាចោទសួរ “ថាតើ តាមច្បាប់ទម្លាប់អន្តរជាតិ ដែលចូលជាធរមាននៅចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ នោះ ការវាយប្រហាររបស់រដ្ឋ ឬ អង្គការទៅលើសមាជិកនៃកងកម្លាំងប្រដាប់អាវុធ*ផ្ទាល់ខ្លួន* អាច ឬក៏មិនអាចជាការវាយប្រហារដែលសំដៅលើប្រជាជនស៊ីវិល បើយោងតាមគោលបំណងនៃមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក”។

២. ខ្ញុំគឺជាប្រធានផ្នែកច្បាប់អន្តរជាតិមកពីមូលនិធិ Challis នៅសាកលវិទ្យាល័យស៊ីដនី និងជាមេធាវីមានជំនាញខាងស្រាវជ្រាវ និងអនុវត្តច្បាប់មនុស្សធម៌អន្តរជាតិ ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ និងសិទ្ធិមនុស្សអន្តរជាតិ។ ប្រវត្តិរូបសង្ខេបខ្លីរបស់ខ្ញុំ មាននៅឧបសម្ព័ន្ធ ៣ (ខ្ញុំអាចផ្តល់ជូនប្រវត្តិរូបសង្ខេបពេញលេញបានប្រសិនបើមានការស្នើសុំ)។

៣. សារណានេះឆ្លើយតបទៅនឹងបញ្ហាចោទក្នុងន័យគាំទ្រ ដោយមានមូលហេតុដូចខាងក្រោម៖

(ក) សេចក្តីសម្រេចមួយចំនួនរបស់តុលាការថ្នាក់ជាតិ បង្ហាញថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អាចប្រព្រឹត្តឡើងប្រសិនបើរដ្ឋវាយប្រហារលើបុគ្គលិកយោធាខ្លួនឯង(យ៉ាងហោចណាស់ធ្វើឡើងនៅខាងក្រៅសកម្មភាពអរិភាព)។

(ខ) ក្នុងករណីដែលការវាយប្រហាររបស់រដ្ឋមកលើយោធាខ្លួនឯង មិនជាប់ពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធនោះ ច្បាប់មនុស្សធម៌អន្តរជាតិមិនយកមកអនុវត្តទេ ហើយនិយមន័យនៃពាក្យថា “ជនស៊ីវិល”នៅក្នុងច្បាប់នេះមិនអាចកំណត់អត្ថន័យនៃពាក្យថា “ជនស៊ីវិល”នៅក្នុងច្បាប់ទម្លាប់អន្តរជាតិស្តីពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិបានឡើយ។

(គ) នៅខាងក្រៅជម្លោះប្រដាប់អាវុធ អត្ថន័យធម្មតានៃពាក្យថា“ប្រជាជនស៊ីវិល”គឺមានអត្ថន័យផ្សេងៗគ្នា។ តាមការបកស្រាយក្នុងន័យចង្អៀត “ជនស៊ីវិល”អាចគ្រាន់តែផ្ទុយពី “យោធា”តែប៉ុណ្ណោះ រួមមានជនគ្រប់គ្រាន់ ក្រៅពីបុគ្គលិកយោធា។ តាមការបកស្រាយក្នុងន័យទូលំទូលាយជាងនេះ ក្នុងការប្រើប្រាស់ជាទូទៅមួយទៀត “ប្រជាជនស៊ីវិល”អាច

យល់បានថា មានន័យថា រួមមាន *អ្នករស់នៅអចិន្ត្រៃយ៍ទាំងអស់របស់ប្រទេសណាមួយ ឬ តំបន់ណាមួយ* ឧទាហរណ៍ "ប្រជាជនស៊ីវិល"របស់ប្រទេសអូស្ត្រាលី។

(ឃ) អត្ថន័យផ្សេងៗគ្នាខាងលើនេះត្រូវតែដោះស្រាយដោយយកតាមការបកស្រាយចុងក្រោយនេះ គឺថា (i) ការបកស្រាយនេះបំពេញបានទាំងស្រុងតាមគោលបំណងនៃច្បាប់ទម្លាប់អន្តរជាតិស្តីពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ពោលគឺការពារសិទ្ធិជាមូលដ្ឋាន និងសេចក្តីថ្លៃថ្នូរមនុស្សជាតិរបស់ជនដែលមិនមានកម្លាំងការពារ កុំឱ្យគាត់ទទួលរងអំពើហិង្សាយ៉ាងរង្គាល និង (ii) ការបកស្រាយនេះចៀសវាងមិនឱ្យមានលទ្ធផលមិនសមហេតុផលដែលការពារជនមួយចំនួនដែលមិនមានកម្លាំងការពារ (ដូចជា នគរបាលស៊ីវិលរបស់រដ្ឋ) កុំឱ្យទទួលរងការវាយប្រហារ ប៉ុន្តែបែរជាមិនការពារជនផ្សេងទៀតដែលមិនមានកម្លាំងការពារដូចគ្នាទៅវិញ (គឺបុគ្គលិកយោធារបស់រដ្ឋដែលស្ថិតនៅខាងក្រៅវង្វង់ច្បាប់មនុស្សធម៌អន្តរជាតិ ហើយជាអ្នកក្រោមបង្គាប់របស់រដ្ឋអំណាច)។

## **ទឡ្ហីករណ៍**

### **ក. យុត្តិសាស្ត្រដែលបកស្រាយថា"ជនស៊ីវិល" រាប់បញ្ចូលទាំងបុគ្គលិកយោធាផ្ទាល់ខ្លួនរបស់រដ្ឋ**

៤. សេចក្តីអំពាវនាវ ធ្វើការអង្កេតយ៉ាងត្រឹមត្រូវថា ទាំង អ.វ.ត.ក ទាំងតុលាការព្រហ្មទណ្ឌ *អន្តរជាតិ*ផ្សេងទៀត មិនទាន់ដោះស្រាយបញ្ហាចោទនេះឱ្យបានច្បាស់លាស់ទេ (នៅកថាខណ្ឌ ៤)។ ប៉ុន្តែ សេចក្តីសម្រេចចំនួនបីរបស់សាលាក្តីថ្នាក់ជាតិមួយដែលអនុវត្តច្បាប់អន្តរជាតិ គឺ តុលាការកំពូលអាល្លឺម៉ង់ នៅក្នុងភូមិភាគកាន់កាប់ដោយចក្រភពអង់គ្លេស បានទទួលស្គាល់ថា បុគ្គលិកយោធាផ្ទាល់ខ្លួនរបស់រដ្ឋណាមួយអាចជាផ្នែកមួយនៃ"ប្រជាជនស៊ីវិលណាមួយ" យោងតាមមាត្រា II(១)(គ)នៃច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យលេខ ១០ (ឆ្នាំ ១៩៤៥)[1]។

---

[1] សំណុំរឿងដើម (ជាភាសាអាល្លឺម៉ង់) នៅឧសម្ព័ន្ធ ១។ រឿងក្តីទាំងនេះត្រូវបានដក់ស្រង់នៅក្នុងសៀវភៅរបស់អ្នកនិពន្ធ Cassese និងអ្នកផ្សេងទៀត ចំណងជើង*ច្បាប់ព្រហ្មទណ្ឌអន្តរជាតិរបស់ Caseses* (បោះពុម្ពលើកទី ៣, OUP, Oxford ឆ្នាំ ២០១៣) ទំព័រ ៩៧ (ជើងទំព័រ ១៦) និងទំព័រ ១០២-១០៣ (ជើងទំព័រ ៤៥) [សូមមើល ឧបសម្ព័ន្ធ ២]។

01298868



(ក) នៅក្នុងរឿងក្តី *R* (ឆ្នាំ ១៩៤៨) [2] សមាជិកម្នាក់នៃអង្គការណាហ្ស៊ីស បានប្រកាសដាក់ទោសមន្ត្រីយោធាម្នាក់ ដោយសារប្រមាថណាហ្ស៊ីសនិយម ហើយបណ្តាលឲ្យមានទោសប្រហារជីវិត។ មានការសម្រេចថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អាចកើតឡើងក្នុងករណីដែលចារីមានចេតនាឲ្យជនរងគ្រោះ ស្ថិតនៅក្រោម"រចនាសម្ព័ន្ធអំណាចមិនអាចគ្រប់គ្រងបាន"របស់រដ្ឋ ដោយដឹងថា ជនរងគ្រោះនឹងត្រូវដាក់ឲ្យស្ថិតនៅក្រោមបង្គាប់របស់ប្រព័ន្ធមួយដែលហិង្សា និងប្រព្រឹត្តតាមអំពើចិត្ត(ទំព័រ ៤៧)។

(ខ) នៅក្នុងរឿងក្តី *P និងអ្នកផ្សេងទៀត* (ឆ្នាំ ១៩៤៨) [3] សមាជិកនៃតុលាការយោធាមួយរបស់អាល្លឺម៉ង់បានដាក់ទោសប្រហារជីវិតទាហានអាល្លឺម៉ង់រត់ចោលជួរចំនួន ៣នាក់ ប្រហែលជានៅជិតពេលដែលអាល្លឺម៉ង់ចុះចាញ់ នៅពេលចុងបញ្ចប់នៃសង្គ្រាម។ តុលាការកំពូលបានរកឃើញយ៉ាងច្បាស់ថា "សកម្មភាពរវាងទាហាន" អាចជាផ្នែកមួយនៃការវាយប្រហារមកលើ"ប្រជាជនស៊ីវិល" ដែលបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្នុងករណីដែលទង្វើនេះជាផ្នែកមួយនៃ"ប្រព័ន្ធព្រហ្មទណ្ឌ"របស់ណាហ្ស៊ីស (នៅកថាខណ្ឌ ២២៨)។ សមាជិកនៃតុលាការយោធានេះបានចូលរួមគំនិតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ពីព្រោះថា ការដាក់ទោសហួសហេតុទាំងនោះគឺជាផ្នែកមួយនៃប្រព័ន្ធយុត្តិធម៌ដ៏ព្រៃផ្សៃ បំភិតបំភ័យរបស់ណាហ្ស៊ីស ដែលបានបង្អាប់សេចក្តីថ្លៃថ្នូរ និងដកហូតលក្ខណៈជាមនុស្សរបស់ជនរងគ្រោះ ព្រមទាំងបដិសេធមិនឲ្យមានមនុស្សធម៌(ទំព័រ ២២០)។

(គ) នៅក្នុងរឿងក្តី *H* (ឆ្នាំ ១៩៤៩) [4] ចៅក្រមអាល្លឺម៉ង់ម្នាក់បានដាក់ទោសប្រហារជីវិតមន្ត្រីកងនាវាអាល្លឺម៉ង់ពីរនាក់ (ដោយសារម្នាក់បានរិះគន់អ៊ីត្លែរ ហើយម្នាក់ទៀតទទួលបានអត្តសញ្ញាណប័ណ្ណបរទេស)។ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អាចកើតឡើងប្រសិនបើចៅក្រមរូបនេះមានចេតនាលើកតម្កើងប្រព័ន្ធហិង្សា និងបំភិតបំភ័យរបស់ណាហ្ស៊ីស។

---

[2] រឿងក្តី *R* ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ១៩៤៨ Entscheidungen in Strafsachen des Obersten Gerichtshofes für die Britische Zone ('Entscheidgunge') វ៉ុល I (W de Gruyter, Berlin, 1949) ទំព័រ ៤៥-៤៩។

[3] រឿងក្តី *P និងអ្នកផ្សេងទៀត* ថ្ងៃទី 0៧ ខែ ធ្នូ ឆ្នាំ ១៩៤៨ Entscheidgunge វ៉ុល I ទំព័រ ២១៧-២២៩។

[4] រឿងក្តី *H* ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ១៩៤៩ Entscheidgunge វ៉ុល II (ឆ្នាំ ១៩៥0) ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ១៩៤៩ ទំព័រ ២៣១-២៤៦។

៥. ការយល់ឃើញខាងលើនេះគឺមានសារៈសំខាន់ណាស់ ពីព្រោះថា វិធានការការពារនៅក្នុងច្បាប់មនុស្សធម៌អន្តរជាតិ(ចូលជាធរមាននៅពេលនោះ) គឺការពាររហូតដល់យុទ្ធជនរបស់គូបដិបក្ខ និងឈ្លើយសឹក ប៉ុន្តែមិនបានការពារបុគ្គលិកយោធារបស់អាល្លឺម៉ង់ ពីការបង្ក្រាបរបស់អាល្លឺម៉ង់ខ្លួនឯងទេ។ ជនរងគ្រោះក៏មិនបានចូលរួមសកម្មភាពអរិភាពប្រដាប់អាវុធប្រឆាំងនឹងរដ្ឋរបស់ខ្លួនឡើយ។ ប៉ុន្តែ ពួកគេមានស្ថានភាពដូចគ្នានឹងពលរដ្ឋអាល្លឺម៉ង់ផ្សេងទៀតដែរ គឺស្ថិតនៅក្រោមបង្គាប់ច្បាប់ជាតិ និងអំណាចច្បាប់របស់អាល្លឺម៉ង់។ បទល្មើសនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បានយកមកអនុវត្តយ៉ាងសមហេតុផលដើម្បីបំពេញចន្លោះប្រហោងនៃវិធានការការពារនៅក្នុងច្បាប់មនុស្សធម៌អន្តរជាតិ។

៦. ពាក់ព័ន្ធនឹងការវាយតម្លៃច្បាប់ទម្លាប់អន្តរជាតិ គឺបញ្ហាថាតើ រដ្ឋនានាបានប្រឆាំងតវ៉ានឹងវិធានមួយដែលទើបចូលជាធរមាន ឬក៏អាចត្រូវគេយល់ឃើញថាបានសុខចិត្តទទួលយកច្បាប់នេះហើយ[5]។ រដ្ឋនានា ហាក់ដូចជាមិនបានជំទាស់ទៅនឹងសេចក្តីសម្រេចទាំងនេះរបស់តុលាការកំពូលអាល្លឺម៉ង់ ដែលបានបោះពុម្ពផ្សព្វផ្សាយទេ ដែលបានសម្រេចចាត់ទុកថា បុគ្គលិកយោធាផ្ទាល់ខ្លួនរបស់រដ្ឋណាមួយ គឺស្ថិតនៅក្នុងវិសាលភាពនៃ“ប្រជាជនស៊ីវិលណាមួយ”។ ការអនុវត្តជារួមតាមរយៈការវិវត្តក្រោយៗមកទៀតដើម្បីរៀបចំក្រមស្តីពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក៏ជាភស្តុតាងបញ្ជាក់ថាខ្វះការជំទាស់ដែរ។

## ខ. ច្បាប់មនុស្សធម៌អន្តរជាតិ មិនអាចកំណត់អត្ថន័យនៃពាក្យថា “ប្រជាជនស៊ីវិល”នៅខាងក្រៅជម្លោះប្រដាប់អាវុធបានឡើយ

៧. ពាក្យថា “ប្រជាជនស៊ីវិលណាមួយ”បានកើតឡើងដើមដំបូងជាធាតុផ្សំមួយនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅពេលដែលឧក្រិដ្ឋកម្មបែបនេះតម្រូវឲ្យមានភាពពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធ(“ភាពពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធ”) គឺតាមមាត្រា ៦(គ) នៃធម្មនុញ្ញ Nuremberg របស់សាលាក្តីយោធាអន្តរជាតិ ឆ្នាំ ១៩៤៥។ ហេតុនេះ នៅពេលនោះ ដើម្បីបកស្រាយអត្ថន័យពាក្យថា“ជនស៊ីវិល” គឺចាំបាច់ត្រូវយោងលើច្បាប់មនុស្សធម៌អន្តរជាតិ ជាច្បាប់ពិសេស(*lex specialis*) ដែលអាចអនុវត្តបាននៅក្នុងជម្លោះប្រដាប់អាវុធ។

[5] រឿងក្តី *នេសាទ អង់ហ្គូ-ន័រវេ (ចក្រភពអង់គ្លេស តទល់នឹង ន័រវេ)* [ឆ្នាំ ១៩៥១] របាយការណ៍តុលាការយុត្តិធម៌អន្តរជាតិ ១១៦ ទំព័រ ១៣៨។

៨. អង្គជំនុំជម្រះសាលាដំបូងរបស់ អ.វ.ត.ក និងសហចៅក្រមស៊ើបអង្កេតអន្តរជាតិ Bohlander បានទទួលស្គាល់យ៉ាងត្រឹមត្រូវថា នៅត្រឹមឆ្នាំ ១៩៧៥ ការវិវត្តជាបន្តបន្ទាប់នៃច្បាប់ទម្លាប់អន្តរជាតិ បានកាត់ផ្តាច់លក្ខខណ្ឌតម្រូវដែលត្រូវមានភាពពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធ[6] ចំណែកឯអង្គបុរេជំនុំជម្រះរបស់ អ.វ.ត.ក មានការជំទាស់[7] ប៉ុន្តែ ការយល់ឃើញបែបនេះរបស់អង្គបុរេជំនុំជម្រះ គឺមិនត្រឹមត្រូវទេបើតាមសំអាងហេតុដែលបានលើកឡើងដោយអង្គជំនុំជម្រះសាលាដំបូង និងចៅក្រម Bohlander ។

៩. នៅពេលដែលគេទទួលស្គាល់ថា ភាពពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធ ត្រូវបានកាត់ផ្តាច់លែងឲ្យមានទៀតហើយនោះ ពាក្យថា "ជនស៊ីវិល" *ចាំបាច់*ត្រូវសន្មតថាមានអត្ថន័យផ្សេងនៅក្នុងបរិបទផ្សេងនៃ*ការវាយប្រហារ ឬអំពើហិង្សានៅខាងក្រៅជម្លោះប្រដាប់អាវុធ*។ ច្បាប់មនុស្សធម៌អន្តរជាតិ អនុវត្ត*តែ*នៅក្នុងជម្លោះប្រដាប់អាវុធ ហើយមិនអនុវត្តនៅក្នុងពេលសន្តិភាព ឬអំពើហិង្សាដែលមិនពាក់ព័ន្ធនឹងជម្លោះណាមួយទេ។ អំពើហិង្សានៅខាងក្រៅជម្លោះប្រដាប់អាវុធ ដែលមិនមានចែងនៅក្នុងច្បាប់មនុស្សធម៌អន្តរជាតិ រួមមាន ក) ដាច់ខាតជាអំពើហិង្សាប្រព្រឹត្តឡើងនៅពេលសន្តិភាព ខ) អំពើហិង្សាដែលរដ្ឋប្រព្រឹត្តមកលើបុគ្គលិកយោធាខ្លួនឯង ដែលមិនពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធនៅក្នុងបរិយាកាសជុំវិញខ្លួន និង (គ) អំពើហិង្សាដែលអង្គការចាត់តាំងឧក្រិដ្ឋជនប្រព្រឹត្តឡើង ឬបណ្តាលមកពីភាពតានតឹងរវាងជនស៊ីវិល ដែលមិនបានកើនឡើងដល់កម្រិតជម្លោះប្រដាប់អាវុធ ហើយមិនមែនជាផ្នែកមួយនៃជម្លោះប្រដាប់អាវុធនៅក្នុងបរិយាកាសជុំវិញខ្លួន។

១០. ជាទូទៅ ច្បាប់មនុស្សធម៌អន្តរជាតិ មិនការពារសមាជិកនៃកងកម្លាំងប្រដាប់អាវុធរបស់រដ្ឋ ដែលជាគោលដៅរបស់រដ្ឋខ្លួនឯងនោះឡើយ។ បញ្ហានេះដោយសារមានមូលហេតុចំនួនពីរ៖

(ក) អំពើហិង្សាផ្ទៃក្នុងមកលើបុគ្គលិកយោធា (រួមមាន"ការបោសសម្អាត") នឹងមិនបង្កើតបានជាជម្លោះប្រដាប់អាវុធមិនមែនអន្តរជាតិ[8] ក្នុងករណីដែលអំពើហិង្សានេះកើតឡើងក្នុងរូប

---

[6] សំណុំរឿង 00១ ឯកសារ E188 សាលក្រម អង្គជំនុំជម្រះសាលាដំបូង អ.វ.ត.ក ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២0១0 កថាខណ្ឌ ២0៩-២៩២។

[7] សំណុំរឿង 00២ ឯកសារ D427/3/15 អ.វ.ត.ក *សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ* ប្រឆាំងនឹងដីកាដំណោះស្រាយ ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២0១១ កថាខណ្ឌ ១៤៤។

[8] យោងតាមអនុសញ្ញាទីក្រុងហ្សឺណែវចំនួន បួន ឆ្នាំ ១៩៤៩ មាត្រា ៣ រួម។

ភាពជាការបង្ក្រាបមានទិសដៅតែមួយមកលើកម្លាំងមិនប្រយុទ្ធ(ដូចជា ការចាប់ខ្លួន ការធ្វើទារុណកម្ម ឬការសម្លាប់) លើកលែងតែសកម្មភាពអរិភាពយ៉ាងខ្លាំងក្លារវាងរដ្ឋជាមួយនឹងក្រុមប្រដាប់អាវុធមានការចាត់តាំង[9] (ដូចជា ក្រុមប្រឆាំងណាមួយនៅក្នុងកងកម្លាំងយោធារបស់រដ្ឋ)។

(ខ) ទោះបីជាថានៅក្នុងបរិយាកាសជុំវិញនោះមានជម្លោះប្រដាប់អាវុធរវាងរដ្ឋពីរក៏ដោយ ក៏ច្បាស់មនុស្សធម៌អន្តរជាតិ ការពារបុគ្គលិកយោធារបស់រដ្ឋនីមួយៗ ពីអំពើហិង្សាមិនស្របច្បាប់របស់រដ្ឋមួយទៀត (ឧទាហរណ៍ តាមរយៈវិធានការការពារឈ្លើយសឹក) ប៉ុន្តែមិនបានការពារបុគ្គលិកយោធាពីអំពើហិង្សារបស់រដ្ឋខ្លួនឯងទេ។ តាមប្រវត្តិសាស្ត្រ ច្បាប់មនុស្សធម៌អន្តរជាតិ បានសន្មតថា ច្បាប់ជាតិនឹងការពារប្រយោជន៍របស់បុគ្គលិកយោធារបស់រដ្ឋខ្លួនឯង ហេតុនេះហើយទើបមិនចាំបាច់ឲ្យច្បាប់មនុស្សធម៌អន្តរជាតិ ចូលអន្តរាគមន៍នៅក្នុងរឿងនេះឡើយ។

១១. ប្រសិនបើច្បាប់មនុស្សធម៌អន្តរជាតិ មិនអនុវត្តនៅក្នុងកាលទេសៈទាំងនេះទេ នោះ (តាមមាត្រា ៥០ នៃ ពិធីសារ I និងបទប្បញ្ញត្តិដែលច្បាប់នេះលើកយោងដើម្បីកំណត់និយមន័យថា ជនស៊ីវិលខុសពីយុទ្ធជន) ការបែងចែកក្រុមមនុស្សជាប្រភេទជនស៊ីវិល គឺមិនអាចកំណត់និយមន័យ"ប្រជាជនស៊ីវិល"នៅក្នុងច្បាប់ទម្លាប់អន្តរជាតិស្តីពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងស្ថានភាពបែបនេះបានឡើយ។ ឧទាហរណ៍ វាមិនសមហេតុដែលនិយាយអំពីជន*បាត់បង់សមត្ថភាពប្រយុទ្ធ* ប្រសិនបើគ្មាន*ការប្រយុទ្ធគ្នា* ឬក៏និយាយអំពីជនដែលចូលរួមសកម្មភាពអរិភាព ប្រសិនបើគ្មានសកម្មភាពអរិភាព ឬក៏លើកឡើងថាជា"សមាជិកនៃកងកម្លាំងប្រដាប់អាវុធរបស់ភាគីណាមួយនៅក្នុង*ជម្លោះ*"(អនុសញ្ញាទីក្រុងហ្សឺណែវ III ឆ្នាំ ១៩៤៩ មាត្រា ៤(១))(ឬក៏ថាជាកម្លាំងតស៊ូ)ប៉ុន្តែបែរជាគ្មានជម្លោះទេ។ ទស្សនទានទាំងនេះមានអត្ថន័យតែក្នុងករណីដែលទស្សនាទានទាំងនេះជាប់ពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធ ដែលបានកំណត់តាមច្បាប់មនុស្សធម៌អន្តរជាតិ និងមានចែងនៅក្នុងច្បាប់នេះ។

១២. ជាការពិតគឺថា សាលាក្តីព្រហ្មទណ្ឌនានា ហាក់ដូចជាបន្តបកស្រាយពាក្យថា "ជនស៊ីវិល"នេះដោយយោងលើច្បាប់មនុស្សធម៌អន្តរជាតិ ទោះបីជាទទួលស្គាល់ថា លក្ខខណ្ឌតម្រូវត្រូវមានភាព

---

[9]លក្ខខណ្ឌសម្រាប់អត្ថិភាពនៃជម្លោះប្រដាប់អាវុធមិនមែនអន្តរជាតិ៖ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Tadic (បណ្តឹងឧទ្ធរណ៍បន្ទាន់លើយុត្តាធិការ)* អង្គជំនុំជម្រះតុលាការកំពូល) IT-94-1 (ថ្ងៃទី ០២ ខែ តុលា ឆ្នាំ ១៩៩៥) កថាខណ្ឌ ៧០។

ពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធ លែងជាផ្នែកមួយនៃច្បាប់ទម្លាប់អន្តរជាតិទៀតហើយ។ អ.វ.ត.ក ក៏បានអនុវត្តតាមវិធីសាស្ត្រនេះដែរ ដោយយល់ឃើញថា "ឋានៈជាជនស៊ីវិលត្រូវបានគេកំណត់តាមរយៈបទប្បញ្ញត្តិនៃច្បាប់ស្តីពីជម្លោះប្រដាប់អាវុធ ជាពិសេសមាត្រា ៥០ នៃពិធីសារបន្ថែម I និងមាត្រា ៤ A នៃអនុសញ្ញាទីក្រុងហ្សឺណែវ III"[10]។

១៣. ប៉ុន្តែ សំខាន់គឺថា រឿងក្តីទាំងអស់ក្នុងចំណោមរឿងក្តីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលបានប្រើប្រាស់និយមន័យរបស់ច្បាប់មនុស្សធម៌អន្តរជាតិស្តីពី "ជនស៊ីវិល" បានប្រើប្រាស់និយមន័យបែបនេះ *ពីព្រោះថា អង្គហេតុនៃរឿងក្តីទាំងនេះគឺទាក់ទងនឹងអំពើដែលពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធដែលមានចែងនៅក្នុងច្បាប់មនុស្សធម៌អន្តរជាតិ*។ នេះរាប់បញ្ចូលទាំងរឿងក្តីទាំងអស់នៅចំពោះមុខតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី("ICTY")។ រឿងក្តីខ្លះបានកំណត់ថា ជនស៊ីវិល មិនរាប់បញ្ចូលសមាជិកនៃកងកម្លាំងប្រដាប់អាវុធ អង្គការតស៊ូ ឬជនបាត់បង់សមត្ថភាពប្រយុទ្ធទេ[11] ដែលប្រភេទជនទាំងនេះត្រូវបានកំណត់និយមន័យតាមច្បាប់មនុស្សធម៌អន្តរជាតិដែលអាចអនុវត្តចំពោះជម្លោះប្រដាប់អាវុធនៅអតីតយូហ្គោស្លាវី។ រឿងក្តីទាំងនេះក៏បានពិនិត្យមើលផងដែរលើច្បាប់មនុស្សធម៌អន្តរជាតិ ដើម្បីកំណត់ថាតើវត្តមានរបស់យុទ្ធជន ឬអតីតយុទ្ធជនក្នុងចំណោមជនស៊ីវិល ធ្វើឲ្យ ប្រជាជនស៊ីវិល បាត់បង់លក្ខណៈជាជនស៊ីវិលដែរឬអត់[12]។ តុលាការ ICTY យល់ឃើញថា ជាការចាំបាច់គឺត្រូវពិចារណាលើភាពស្របច្បាប់នៃការវាយប្រហារ តាមច្បាប់មនុស្សធម៌អន្តរជាតិ ដើម្បីកំណត់ថាតើ អំពើហិង្សាមកលើជនស៊ីវិល *នៅក្នុងអំឡុងពេល*

---

[10] សំណុំរឿង ០០១ ឯកសារ E188 សាលក្រម អង្គជំនុំជម្រះសាលាដំបូង អ.វ.ត.ក ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៣០៤។

[11] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Martić,* IT-95-11-A សាលដីកា អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០០៨ កថាខណ្ឌ ៣០៧។ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Mrksić,* IT-95-13-1-A សាលដីកា ថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០០៩ កថាខណ្ឌ ២៥។ រឿងក្តី *រដ្ឋអាជ្ញាតទល់នឹង Galić,* IT-98-29-A សាលដីកា អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៦ កថាខណ្ឌ ១៣៧។ រឿងក្តី *រដ្ឋអាជ្ញាតទល់នឹង Blaškić,* IT-95-14-A, សាលដីកា អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០០៤ កថាខណ្ឌ ១១៣។

[12] បណ្តឹងឧទ្ធរណ៍ *Blaškić* ដូចជើងទំព័រខាងលើ កថាខណ្ឌ ១១៣-១១៤។ សូមមើលផងដែរ ពិធីសារបន្ថែម I ឆ្នាំ ១៩៧៧ មាត្រា ៥០(៣)។

*ជម្លោះ* បង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែរឬអត់[13]។ អ.វ.ត.ក បានអនុវត្តតាមវិធីសាស្ត្រនេះ[14]។

១៤. គួរឲ្យកត់សម្គាល់ថា មាត្រា ៥ នៃលក្ខន្តិកៈតុលាការ ICTY ឆ្នាំ ១៩៩៣ កម្រិតយុត្តាធិការរបស់តុលាការនេះនៅត្រឹមឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ "នៅពេលដែលប្រព្រឹត្តឡើងនៅក្នុងជម្លោះប្រដាប់អាវុធ"។ មានការទទួលស្គាល់ថា ចំណុចនេះត្រូវបានតុលាការ ICTY បកស្រាយថាជាលក្ខខណ្ឌតម្រូវយុត្តាធិការ មិនមែនជាធាតុផ្សំនៃបទល្មើសទេ[15] ដូច្នេះចាំបាច់គ្រាន់តែត្រូវបង្ហាញថាមានជម្លោះប្រដាប់អាវុធមួយកើតឡើង ហើយសកម្មភាពរបស់ជនជាប់ចោទ"គឺជាប់ពាក់ព័ន្ធផ្នែកភូមិសាស្ត្រ និងពេលវេលាផងដែរ"ជាមួយនឹងបទល្មើស[16]។ តុលាការ ICTY បានទទួលស្គាល់ថែមទៀតថា ភាពពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធ មិនតម្រូវឲ្យមានទេតាមច្បាប់ទម្លាប់អន្តរជាតិ[17]។ បន្ថែមពីលើនេះទៀត តុលាការ ICTY បានបង្ហាញថា អត្ថន័យនៃពាក្យថា "ជនស៊ីវិល"តាមច្បាប់មនុស្សធម៌អន្តរជាតិ និងច្បាប់ស្ដីពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មិនគួរកំណត់និយមន័យឲ្យមាន"អត្ថន័យផ្សេងៗគ្នា"ឡើយ[18]។ ប៉ុន្តែ ការពិតនៅតែថា អង្គហេតុនៃរឿងក្ដីពាក់ព័ន្ធទាំងអស់របស់តុលាការ ICTY *ចាំបាច់ត្រូវ*យោងលើច្បាប់មនុស្សធម៌អន្តរជាតិ ពីព្រោះថា អង្គហេតុទាំងនោះជាប់ពាក់ព័ន្ធផ្ទាល់ជាមួយនឹងជម្លោះប្រដាប់អាវុធ។ ហេតុនេះ អង្គហេតុទាំងនោះមិនពាក់ព័ន្ធនឹងនិយមន័យនៃពាក្យថា "ប្រជាជនស៊ីវិល"នៅខាងក្រៅជម្លោះប្រដាប់អាវុធ ដែលមានចែងនៅក្នុងច្បាប់មនុស្សធម៌អន្តរជាតិទេ។

---

[13]រឿងក្ដី *រដ្ឋអាជ្ញាតទល់នឹង Kunarac*, IT-96-23 & IT-96-23/1-A, សាលដីកា អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២00២ កថាខណ្ឌ ៩១។

[14]សំណុំរឿង 00១ ឯកសារ E188 សាលក្រម អង្គជំនុំជម្រះសាលាដំបូង អ.វ.ត.ក ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២0១0 កថាខណ្ឌ ៣0៨។

[15] រឿងក្ដី *រដ្ឋអាជ្ញា តទល់នឹង Tadic*, IT-94-1-A សាលដីកា អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៩ កថាខណ្ឌ ២៤៩។ រឿងក្ដី *រដ្ឋអាជ្ញាតទល់នឹង Kunarac*, IT-96-23 & IT-96-23/1-A, សាលដីកា អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២00២ កថាខណ្ឌ ៨៣។

[16] បណ្ដឹងឧទ្ធរណ៍ *Kunara* ជើងទំព័រ ១៣ ខាងលើ កថាខណ្ឌ ៨៣។ រឿងក្ដី *រដ្ឋអាជ្ញា តទល់នឹង Tadic*, IT-94-1-A សាលដីកា អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៩ កថាខណ្ឌ ២៤៩។

[17] រឿងក្ដី *Tadic* ដូចជើងទំព័រខាងលើ កថាខណ្ឌ ២៥១។ រឿងក្ដី *Tadic* ជើងទំព័រ ៩ ខាងលើ កថាខណ្ឌ ១៤១។

[18] បណ្ដឹងឧទ្ធរណ៍ *Martić* ជើងទំព័រ ១១ ខាងលើ កថាខណ្ឌ ២៩៩។

## គ. អត្ថន័យឯករាជ្យនៃពាក្យថា "ប្រជាជនស៊ីវិល"នៅខាងក្រៅជម្លោះប្រដាប់អាវុធ និងច្បាប់មនុស្សធម៌អន្តរជាតិ

១៥. អត្ថន័យនៃពាក្យថា "ប្រជាជនស៊ីវិលណាក៏ដោយ" គឺត្រូវកើតចេញពីច្បាប់ទម្លាប់អន្តរជាតិស្តីពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅពេលវេលាពាក់ព័ន្ធនោះ[19]។ ដាច់ខាត បញ្ហានេះមិនមែនជាបញ្ហា *ការបកស្រាយ*ទេ ពីព្រោះថា ការបកស្រាយគឺពាក់ព័ន្ធនឹងអត្ថបទជាលាយលក្ខណ៍អក្សរ (សន្ធិសញ្ញា ឬលក្ខន្តិកៈ)[20] ប៉ុន្តែវាជាការកំណត់លើការអនុវត្តរបស់រដ្ឋ និង *គតិច្បាប់*(*opinio juris*) អំពីខ្លឹមសារនៃវិធាននៅក្នុងច្បាប់ទម្លាប់អន្តរជាតិ។ រឿងក្តីនានាខាងលើរបស់តុលាការកំពូលអាល្លឺម៉ង់ផ្តល់សិទ្ធិអំណាចជាផ្លូវការថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អាចរាប់បញ្ចូលទាំងអំពើហិង្សារបស់រដ្ឋមកលើកងកម្លាំងយោធាខ្លួនឯង នៅខាងក្រៅសកម្មភាពអរិភាពដែលមានចែងនៅក្នុងច្បាប់មនុស្សធម៌អន្តរជាតិ។ តាមរយៈនេះ ការអនុវត្តបានបង្កើតខ្លឹមសារនៃវិធាននៅក្នុងច្បាប់ទម្លាប់អន្តរជាតិស្តីពីវិសាលភាពនៃពាក្យថា "ប្រជាជនស៊ីវិលណាក៏ដោយ"។

១៦. សំណួរមួយនៅតែចោទសួរថាតើ រឿងក្តីទាំងនោះអាច ឬក៏មិនអាចមានហេតុផលសមស្របធ្វើឱ្យត្រូវគ្នាជាមួយអត្ថន័យខ្លឹមសារធម្មតានៃពាក្យថា "ប្រជាជនស៊ីវិល"ដែលជាផ្នែកមួយនៃវិធាននៅក្នុងច្បាប់ទម្លាប់អន្តរជាតិ។ នៅត្រឹមចំណុចដែលផ្នែកនេះនៅក្នុងវិធាននៃច្បាប់ទម្លាប់អន្តរជាតិ ត្រូវបានយកមកឆ្លុះបញ្ចាំងនៅក្នុងការកំណត់ក្រមអំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្នុងលិខិតុបករណ៍អន្តរជាតិ (រួមមាន លិខិតុបករណ៍អន្តរជាតិដែល អ.វ.ត.ក ពិនិត្យមើលផងដែរនោះ[21]) ការបក

---

[19] សំណុំរឿង ០០២ ឯកសារ E313 សាលក្រម អង្គជំនុំជម្រះសាលាដំបូង អ.វ.ត.ក ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ១៨ ( "អនុលោមតាមកិច្ចព្រមព្រៀង [រវាងអង្គការសហប្រជាជាតិ ជាមួយនឹងកម្ពុជា] អ្នកបង្កើតច្បាប់កម្ពុជាច្បាស់ជាមានគោលបំណងផ្តល់យុត្តាធិការទៅ អ.វ.ត.ក លើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដូចមានចែងនៅក្នុងច្បាប់អន្តរជាតិ")។ សូមមើលផងដែរ កថាខណ្ឌ ១០០។

[20] យុត្តាធិការរបស់ អ.វ.ត.ក មានមូលដ្ឋាននៅក្នុងច្បាប់ទម្លាប់អន្តរជាតិស្តីពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ហេតុនេះ អ.វ.ត.ក មិនមែនបកស្រាយពាក្យពេចន៍នៅក្នុងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ ជាមួយនឹងកម្ពុជា ឬនៅក្នុងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ទេ។ អ.វ.ត.ក បានបង្ហាញពីគោលការណ៍នៃការបកស្រាយច្បាប់លក្ខន្តិកៈនៅក្រោមច្បាប់ជាតិរបស់កម្ពុជា៖ *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី* អង្គបុរេជំនុំជម្រះ អ.វ.ត.ក ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ ឯកសារ D427/1/30 កថាខណ្ឌ ១២២ ("ត្រូវប្រកាន់ខ្ជាប់អត្ថន័យនៃពាក្យតាមវេយ្យាករណ៍ និងតាមន័យធម្មតា លើកលែងតែថាវាអាចនាំឱ្យមានភាពមិនសមហេតុផល ឬភាពមិនស៊ីសង្វាក់គ្នា")។

[21] សំណុំរឿង ០០១ ឯកសារ E188 សាលក្រម អង្គជំនុំជម្រះសាលាដំបូង អ.វ.ត.ក ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ២៨៥-២៨៨។ សំណុំរឿង ០០១/១៨-០៧-២០០៧-អ.វ.ត.ក-អ.ជ.ត.ក សាលដីកា អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី ០៣ ខែ

ស្រាយលិខិតុបករណ៍ទាំងនោះអាចជួយបំភ្លឺអំពីច្បាប់ទម្លាប់អន្តរជាតិ[22]។ សន្ធិសញ្ញាណាមួយ“ត្រូវបកស្រាយដោយសុច្ឆន្ទៈ ស្របតាមអត្ថន័យធម្មតាដែលឱ្យនិយមន័យទៅលើពាក្យពេចន៍នៃសន្ធិសញ្ញានោះនៅក្នុងបរិបទនៃពាក្យពេចន៍ទាំងនោះ ហើយដោយពិនិត្យមើលវត្ថុបំណង និងគោលបំណងនៃសន្ធិសញ្ញានោះ” [23]។

១៧. អត្ថន័យធម្មតានៃពាក្យថា “ប្រជាជនស៊ីវិល”នៅក្រៅច្បាប់មនុស្សធម៌អន្តរជាតិ គឺ*មានន័យផ្សេងៗគ្នា* ពីព្រោះថា អាចមានការយល់ឃើញជាច្រើនខុសគ្នាអំពីអត្ថន័យនេះនៅក្នុងការប្រើប្រាស់ជាទូទៅ(ហើយមិនមាននិយមន័យច្បាប់ជាទូទៅអំពីពាក្យថា “ជនស៊ីវិល”ទេនៅក្នុងច្បាប់អន្តរជាតិសាធារណៈ)។ តាមការបកស្រាយក្នុងន័យចង្អៀត “ជនស៊ីវិល”អាចគ្រាន់តែមានន័យផ្ទុយពី “យោធា”តែប៉ុណ្ណោះ គឺរួមមានជនទាំងអស់ក្រៅពីបុគ្គលិកយោធា។ ហេតុនេះហើយទើបវចនានុក្រមភាសាអង់គ្លេសអុកស្វឺដ (បង្ហាញថា ជនស៊ីវិល គឺជា “ជនដែលមិនមានការងារអាជីពនៅក្នុងកងកម្លាំងប្រដាប់អាវុធ ជាជនដែលមិនមែនជាយោធា”[24]។ តាមការបកស្រាយទីពីរ ក្នុងន័យកាន់តែចង្អៀតជាងនេះ វចនានុក្រមភាសាអង់គ្លេសអាមេរិកអាជ្ញានិយម ឈ្មោះ Meeriam Webster's កំណត់និយមន័យថា ជនស៊ីវិល គឺជាជនដែលមិនរាប់បញ្ចូលសមាជិកនៃ“កងកម្លាំងយោធា ឬនគរបាល ឬកងពន្លត់អគ្គិភ័យ” [25]។

១៨. តាមការបកស្រាយទី៣ ក្នុងន័យទូលំទូលាយជាងនេះវិញ នៅក្នុងការប្រើប្រាស់ជាទូទៅមួយផ្សេងទៀត ពាក្យថា “ប្រជាជនស៊ីវិល”អាចយល់បានថាមានន័យថាជា *អ្នករស់នៅប្រទេសណាមួយ ឬតំបន់ណាមួយ* ឧទាហរណ៍ “ប្រជាជនស៊ីវិល”របស់ប្រទេសអូស្ត្រាលី។ ឧទាហរណ៍ វចនានុក្រមភាសាបារាំងអាជ្ញានិយមបំផុតឈ្មោះ *Dictionnaire de L' Académie française* កំណត់និយម

---

កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ១០៣, ១០៨-១១៦។ សំណុំរឿង ០០៣/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស ដីកាសម្រេចលើសំណើរបស់ មាស មុត សុំបញ្ជាក់បំភ្លឺទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងភាពពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធ ថ្ងៃទី០៥ ខែ មេសា ឆ្នាំ ២០១៦ កថាខណ្ឌ ២៣-៧១។

[22] បណ្ដឹងឧទ្ធរណ៍ *Martić* ជើងទំព័រ ១១ ខាងលើ កថាខណ្ឌ ២៩៥។

[23] អនុសញ្ញាទីក្រុងវីយែនស្ដីពីច្បាប់អនុសញ្ញា ឆ្នាំ ១៩៦៩ មាត្រា ៣១(១)។ បន្ថែមពីលើនេះទៀត “មធ្យោបាយបន្ថែមសម្រាប់ការបកស្រាយ រាប់បញ្ចូលទាំងការងាររៀបចំសន្ធិសញ្ញា និងកាលៈទេសៈនៃការបញ្ចប់សន្ធិសញ្ញា”អាចយកមកប្រើប្រាស់ក្នុងករណីដែលអត្ថន័យធម្មតា “នាំឱ្យមានលទ្ធផលមួយដែលខុសធម្មតា ឬមិនសមហេតុផលយ៉ាងខ្លាំង”៖ មាត្រា ៣២។

[24] វចនានុក្រមភាសាអង់គ្លេស អុកស្វឺដ តាមអ៊ីនធឺណែត។

[25] វចនានុក្រម Meeriam Webster's តាមអ៊ីនធឺណែត។

ន័យលើពាក្យ"ជនស៊ីវិល"ថាជា *[q]ui concerne la cité, la communauté nationale. La vie, La socitété civile. L'ordre civil...*" (ជនដែលពាក់ព័ន្ធនឹងទីក្រុង សហគមន៍ជាតិ។ *ជីវិតសង្គមស៊ីវិល*។ សណ្តាប់ធ្នាប់ស៊ីវិល...) [26]។ ដូចគ្នានេះដែរ បុគ្គលិកយោធាគឺជាផ្នែកមួយនៃជីវិតរបស់សហគមន៍ជាតិ ក្រៅពីបរិបទច្បាប់ពិសេសនៃច្បាប់មនុស្សធម៌អន្តរជាតិ។ ក្នុងន័យនេះ "ជនស៊ីវិល"គឺនៅជាប់គ្នាជាមួយនឹង "ប្រជាជន"ដោយមិនអាចបំបែកបានទេ។ ផ្ទុយមកវិញ ជាធម្មតាគេនឹងមិននិយាយពាក្យថា "យោធា- military population"ទេនៅពេលដែលមានសន្តិភាព។ នៅក្នុងរដ្ឋជាច្រើន បុគ្គលិកយោធា(ដូចជា នគរបាល និងអ្នកពន្លត់អគ្គិភ័យ)នឹងត្រូវអ្នកផ្សេងចាត់ទុកថាជាផ្នែកមួយនៃ"ប្រជាជនស៊ីវិល"ធម្មតា ហើយពួកគាត់ចាត់ទុកខ្លួនឯងដូច្នេះដែរ។

១៩. គុណនាមនៃពាក្យ"ជនស៊ីវិល"គឺជាពាក្យសិល្បៈផ្នែកច្បាប់នៅក្នុងច្បាប់មនុស្សធម៌អន្តរជាតិ ប៉ុន្តែនៅខាងក្រៅជម្លោះប្រដាប់អាវុធ អត្ថន័យនៃពាក្យនេះប្រែប្រួល ហេតុនេះ ពាក្យនេះគឺជាការសរសេរកាត់រៀបរាប់ពីប្រជាជនទូទាំងរបស់ប្រទេសណាមួយ ឬតំបន់ណាមួយ។ ត្រង់ចំណុចនេះ ខ្លឹមសារសំខាន់គឺថា នៅក្នុងអំឡុងពេលរៀបចំសេចក្តីព្រាងលក្ខន្តិកៈទីក្រុងរ៉ូម របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ប្រតិភូមួយចំនួនជឿថា ពាក្យថា ប្រជាជន"ស៊ីវិល" គឺមានន័យមិនច្បាស់ មិនមានភាពចាំបាច់ ហើយធ្វើឲ្យមានការភាន់ច្រឡំ ពីព្រោះថា ពាក្យនេះផ្តល់តម្រុយថា ត្រូវតម្រូវឲ្យមានជម្លោះប្រដាប់អាវុធចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[27]។

២០. ក្នុងការដោះស្រាយបញ្ហាអត្ថន័យផ្សេងគ្នានៃពាក្យថា "ប្រជាជនស៊ីវិល" គឺត្រូវតែយកអត្ថន័យដែលស្របគ្នាបំផុតជាមួយនឹងគោលបំណងនៃច្បាប់ទម្លាប់អន្តរជាតិស្តីពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ច្បាប់នេះមានបំណងការពារសិទ្ធិជាសារវ័ន្ត និងសេចក្តីថ្លៃថ្នូរមនុស្សជាតិ ប្រឆាំងនឹងអំពើហិង្សាជាប្រព័ន្ធ ជាពិសេសការពារជនដែលមិនមានកម្លាំងការពារតទល់នឹងរដ្ឋអំណាច[28]។ ដើម្បីសម្រេចគោលបំណងនេះ ច្បាប់នេះបានបង្កើតឡើងជាពិសេសដើម្បីបំពេញចន្លោះប្រហោងនៅក្នុងបទប្បញ្ញត្តិនៃច្បាប់ស្តីពីឧក្រិដ្ឋកម្មសង្គ្រាមនៅពេលនោះ គឺការពារប្រជាជនស៊ីវិលផ្ទាល់ខ្លួនរបស់រដ្ឋ

---

[26] *Dictionnaire de L' Académie française* (បោះពុម្ពលើកទី ៩) តាមអ៊ីនធឺណែត។

[27] សូមមើល W Schabas *តុលាការព្រហ្មទណ្ឌអន្តរជាតិ ៖ មតិយោបល់លើលក្ខន្តិកៈទីក្រុងរ៉ូម* (OUP អុកស្វ៊ដ ឆ្នាំ ២០១០) ទំព័រ ១៥២-១៥៣។

[28] G Werle *គោលការណ៍នៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ* (TMC Asser Press ទីក្រុងអាឡេ ឆ្នាំ ២០០៥) ទំព័រ ២២២ និង ២៩៥។

ណាមួយ[29]។ ហេតុនេះ ក្នុងករណីដែលវិធានការការពារនៅក្នុងច្បាប់មនុស្សធម៌អន្តរជាតិ មិនអនុវត្តចំពោះបុគ្គលិកយោធាដែលទទួលរងការវាយប្រហារពីរដ្ឋខ្លួនឯងនោះ គឺត្រូវយកការបកស្រាយក្នុងន័យទូលំទូលាយថា"ប្រជាជនស៊ីវិល"គឺជាអ្នករស់នៅទាំងអស់របស់ប្រទេសណាមួយ ឬតំបន់ណាមួយ។ ការបកស្រាយបែបនេះបំពេញចន្លោះប្រហោងនៅក្នុងច្បាប់មនុស្សធម៌អន្តរជាតិ បានយ៉ាងល្អបំផុត ដើម្បីផ្តល់កិច្ចការពារមនុស្សធម៌ដល់បុគ្គលិកយោធាដែលមិនមានកម្លាំងការពារ ហើយជាអ្នកក្រោមបង្គាប់របស់រដ្ឋអំណាចខ្លួនឯង ប៉ុន្តែមិនបានធ្វើសង្គ្រាមជាមួយនឹងរដ្ឋអំណាចទេ។

២១. ការបកស្រាយពាក្យថា"ជនស៊ីវិល"នៅក្រៅច្បាប់មនុស្សធម៌អន្តរជាតិ ដោយមិនរាប់បញ្ចូលបុគ្គលិកយោធានោះ នឹងនាំឲ្យមានលទ្ធផលមិនសមហេតុផលផងដែរ ហេតុនេះត្រូវតែចៀសវាងការបកស្រាយបែបនេះ។ ឧទាហរណ៍ នៅពេលដែលមានសន្តិភាព សមាជិកនៃកងកម្លាំងនគរបាល ជាទូទៅត្រូវបានបំពាក់អាវុធ និងផ្តល់សិទ្ធិអំណាចឲ្យប្រើប្រាស់កម្លាំង ចំណែកឯ បុគ្គលិកយោធាវិញ ជាទូទៅមិនត្រូវបានបំពាក់អាវុធ និងផ្តល់សិទ្ធិអំណាចឲ្យប្រើប្រាស់កម្លាំងទេនៅខាងក្រៅសង្គ្រាម។ ប៉ុន្តែ នគរបាល ជាទូទៅត្រូវគេចាត់ទុកថាជាជនស៊ីវិល នៅខាងក្រៅសង្គ្រាម[30]។ វាមិនសមហេតុផលប្រសិនបើចាត់ទុកថា បុគ្គលិកយោធាដែលមិនមានបំពាក់អាវុធ គឺមិនមែនជាជនស៊ីវិលទេ ដោយសារតែថា ពួកគាត់ទទួលបានការងារជាផ្លូវការពីយោធា តាមច្បាប់ជាតិ ហើយមិនគិតពីមុខងារជាក់ស្តែងរបស់ពួកគាត់នោះទេ។

២២. អត្ថន័យទីពីរ ទូលំទូលាយជាងអំពីពាក្យថា "ប្រជាជនស៊ីវិល" ក៏មិនរំលោភលើគោលការណ៍នីត្យានុកូលភាព តាមច្បាប់កម្ពុជា និងច្បាប់អន្តរជាតិដែរ គឺថា ច្បាប់ដែលពាក់ព័ន្ធនឹងឧក្រិដ្ឋកម្ម ត្រូវ

---

[29] សំណុំរឿង ០០១ ឯកសារ E188 សាលក្រម អង្គជំនុំជម្រះសាលាដំបូង អ.វ.ត.ក ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៣១២ ដកស្រង់រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Mrksić,* IT-95-13-1-T សាលក្រម អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៧ កថាខណ្ឌ ៤៤១។

[30] ក៏នៅក្នុងជម្លោះប្រដាប់អាវុធដែរ៖ សំណុំរឿង ០០១ ឯកសារ E188 សាលក្រម អង្គជំនុំជម្រះសាលាដំបូង អ.វ.ត.ក ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៣០៤។ សូមមើលផងដែរ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Norman និងអ្នកផ្សេងទៀត* SCSL-04-14-A សាលក្រម ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០០៨ កថាខណ្ឌ ២៦២ ("ការសន្មតជាទូទៅគឺថា ភ្នាក់ងារអនុវត្តច្បាប់ប្រដាប់អាវុធរបស់រដ្ឋណាមួយ ត្រូវបានចាត់ទុកថាជាជនស៊ីវិល តាមគោលបំណងនៃច្បាប់មនុស្សធម៌អន្តរជាតិ")។

មានភាព"ច្បាស់លាស់ ពិតប្រាកដ និងមិនប្រតិសកម្ម"[31]។ គោលការណ៍នេះមិនហាមឃាត់ អ.វ.ត.ក មិនឱ្យ"បកស្រាយ ឬបំភ្លឺច្បាប់ ឬក៏មិនឱ្យពឹងផ្អែកលើសេចក្តីសម្រេចដែលបកស្រាយ ឬបំភ្លឺច្បាប់នៅក្នុងរឿងក្តីផ្សេងទេ"ប្រសិនបើទង្វើបែបនេះមិនបាន"បង្កើតច្បាប់ថ្មី ឬ...បកស្រាយច្បាប់ដែលមានស្រាប់ឱ្យហួសពីដែនកំណត់នៃការបំភ្លឺដ៏សមហេតុផល"[32]។ នៅចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ គេអាចប្រមើលបានទាំងស្រុងថា សមាជិកដែលមិនមានកម្លាំងការពារនៅក្នុងយោធារបស់រដ្ឋណាមួយ (ហើយជាអ្នកក្រោមបង្គាប់របស់រដ្ឋអំណាចនោះ) និងមិនស្ថិតនៅក្នុងជម្លោះប្រដាប់អាវុធប្រឆាំងនឹងរដ្ឋ ហើយក៏មិនទទួលបានការការពារពីច្បាប់មនុស្សធម៌អន្តរជាតិ) គឺជាជនដែលអាចជាផ្នែកមួយនៃប្រជាជនស៊ីវិល មានន័យថា ជាអ្នករស់នៅផ្ទាល់ខ្លួនរបស់រដ្ឋនោះ ហើយជាគោលដៅនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិរបស់រដ្ឋដែលចូលរួមអំពើហិង្សាយ៉ាងរង្គាល។

២៣. ដើម្បីឱ្យចប់សព្វគ្រប់ គេចងចាំថា ច្បាប់អន្តរជាតិមិនតម្រូវថា "បុគ្គលជាជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវតែជាជនស៊ីវិល"នោះទេ[33] ប៉ុន្តែ ការវាយប្រហារនេះមានគោលដៅសំដៅលើប្រជាជនស៊ីវិល ក្នុងចំណោមនោះអាចមិនមែនជាជនស៊ីវិល។ ហេតុនេះ ចាំបាច់ត្រូវកំណត់ថាតើការវាយប្រហាររបស់រដ្ឋមកលើបុគ្គលិកយោធា មាន ឬក៏មិនគោលដៅសំដៅលើពួកគាត់ *ជា* ជនស៊ីវិល ឬក៏ជាបុគ្គលិកយោធានៅក្នុងចំណោមប្រជាជនស៊ីវិល។

## សេចក្តីសន្និដ្ឋាន

២៤. ច្បាប់ទម្លាប់អន្តរជាតិស្តីពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ បានបញ្ចូលជាជនស្ថិតនៅក្នុងចំណោម "ប្រជាជនស៊ីវិល"នូវបុគ្គលិកយោធារបស់រដ្ឋដែលត្រូវទទួលរងអំពើហិង្សាពីរដ្ឋខ្លួនឯង ក្នុងករណីដែលអំពើហិង្សានេះមិនពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធ ហើយមិនមានចែងនៅក្នុងច្បាប់មនុស្សធម៌អន្តរជាតិ។ សេចក្តីសន្និដ្ឋាននេះ មានការគាំទ្រពី (ក) សេចក្តីសម្រេចចំនួនបីរបស់តុលាការកំពូលអាល្លឺម៉ង់ នៅក្នុងឆ្នាំ ១៩៤៨-៤៩ ដែលមិនមានការជំទាស់ពី

---

[31] សំណុំរឿង ០០២ ឯកសារ E313 សាលក្រម អង្គជំនុំជម្រះសាលាដំបូង អ.វ.ត.ក ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ១៦។

[32] ដូចជើងទំព័រខាងលើ។ ស្រដៀងគ្នានេះដែរ សូមមើល សំណុំរឿង ០០១/១៨-០៧-២០០៧-អ.វ.ត.ក-អ.ជ.ត.ក សាលដីកាអង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ២៣៥។

[33] បណ្តឹងឧទ្ធរណ៍ *Mrksić* ជើងទំព័រ ១១ ខាងលើ កថាខណ្ឌ ៣០៧។ បណ្តឹងឧទ្ធរណ៍ *Mrksić* ជើងទំព័រ ១១ ខាងលើ កថាខណ្ឌ ៣២ ។

រដ្ឋផ្សេងទៀត (ខ) ការបែកចែកឲ្យខុសគ្នាយ៉ាងសមហេតុផលរវាងអត្ថន័យពិសេសនៃពាក្យថា "ជនស៊ីវិល"តាមច្បាប់មនុស្សធម៌អន្តរជាតិ ជាមួយនឹងអត្ថន័យនៃពាក្យនេះនៅក្រៅច្បាប់មនុស្សធម៌អន្តរជាតិ និង (គ) ការបកស្រាយក្នុងន័យធម្មតាអំពីពាក្យថា "ប្រជាជនស៊ីវិល"នៅខាងក្រៅជម្លោះប្រដាប់អាវុធ។ សេចក្តីសន្និដ្ឋានេះក៏ដោះស្រាយបញ្ហាអត្ថន័យផ្សេងៗគ្នា យោងតាមគោលបំណងនៃច្បាប់ស្តីពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (ដើម្បីពង្រីកវិធានការការពារសិទ្ធិមនុស្ស និងសេចក្តីថ្លៃថ្នូរមនុស្សជាតិឲ្យហួសពីវិធានការការពារដែលនៅមាននៅក្នុងច្បាប់មនុស្សធម៌អន្តរជាតិ ) ហើយបំពេញតាមតម្រូវចាំបាច់ដែលត្រូវចៀសវាងលទ្ធផលមិនសមហេតុផល(ដែលចាត់ទុកនគរបាលបំពាក់អាវុធ ថាជា"ជនស៊ីវិល"នៅខាងក្រៅសង្គ្រាម ប៉ុន្តែបែរជាមិនរាប់បញ្ចូលបុគ្គលិកយោធាដែលមិនមានបំពាក់អាវុធ ថាជាជនស៊ីវិលទៅវិញ ដោយសារមូលហេតុឋានៈផ្លូវការរបស់ពួកគាត់ ដោយមិនគិតពីទង្វើជាក់ស្តែងរបស់ពួកគាត់ ឬការចូលរួមអំពើហិង្សារបស់រដ្ឋ ឬឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ)។

| **កាលបរិច្ឆេទ** | **ឈ្មោះ** | **ទីកន្លែង** | **ហត្ថលេខា** |
|---|---|---|---|
| ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៦ | សាស្ត្រាចារ្យ Ben Saul | ស៊ីដនី ប្រទេសអូស្ត្រាលី | *[ហត្ថលេខា]* |

ឯកសារភ្ជាប់ជាមួយ៖

- តារាងសិទ្ធិអំណាច (២ ទំព័រ)
- ឧបសម្ព័ន្ធ ១៖ សេចក្តីសម្រេចនានារបស់តុលាការកំពូលអាល្លឺម៉ង់ (១៨ ទំព័រ)
- ឧបសម្ព័ន្ធ ២៖ ឯកសារដកស្រង់ពីច្បាប់ព្រហ្មទណ្ឌអន្តរជាតិរបស់ *Cassese* (២ ទំព័រ)
- ឧបសម្ព័ន្ធ ៣៖ ប្រវត្តិរូបសង្ខេប( ១ ទំព័រ)